**សលាកប័ត្រព័ត៌មាន៖** ការប្រើអំពើហិង្សាឆ្លើយតបនឹងការតវ៉ារបស់កម្មករ កម្មការិនី

**កាលបរិច្ឆេទ៖** ខែ កក្កដា ឆ្នាំ ២០១២

**រូបភាពរួម៖** ការប៉ុនប៉ងនាពេលថ្មីៗនេះរបស់អាជ្ញាធរដោយប្រើអំពើហិង្សាដើម្បីបង្ក្រាបលើការធ្វើបាតុកម្មរបស់កម្មករ កម្មការិនី ដែលរួមបញ្ចូលទាំង វាយ ដំ និង ការចាប់ខ្លួនបាតុករ ជាករណីមួយក្នុងចំណោមករណីជាច្រើន ដែលកើតមានទូទាំងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ដែលបញ្ជាក់ថាជារឿយៗអាជ្ញាធរមិនគោរពសិទ្ធិសេរីភាពនៃការប្រជុំដោយសន្តិវិធី។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះពណ៌នាអំពីទិដ្ឋភាពទូទៅនៃការធ្វើបាតុកម្មដោយសន្តិវិធី កាលពីថ្ងៃទី១១ ខែ ក ក្កដា ឆ្នាំ២០១២ របស់ កម្មករកម្មការិនីនៃរោងចក្រ តៃ យៀន (ថ្មីៗនេះប្តូរឈ្មោះមកជា តៃណាន) ដែលពេលនោះលោក វ៉ុង បញ្ញា ជាបុគ្គលិកនៃសហភាពសហជីព កម្ពុជា (ស.ស.ក) ត្រូវបាន អាជ្ញាធរវាយធ្វើបាប និងចាប់ខ្លួន។ ព្រឹត្តិការណ៍នេះ គឺជាការព្យាយាមកម្រិតកំពូលរបស់មន្ត្រីអនុវត្តច្បាប់ ក្នុងការ បំបែកក្រុមបាតុករដោយបំពានលើច្បាប់ជាតិ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធី។ សលាកប័ត្រនេះត្រូវបានតាក់តែងឡើងដោយ ម.ស.ម.ក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅប្រទេសកម្ពុជា ។

## សាវតារនៃករណី

ចាប់តាំងពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១២ កម្មករ កម្មការិនី មកពីរោងចក្រដែលទើបនឹងបានប្តូរឈ្មោះទៅជា តៃណាន ដែលជារោងចក្រផ្គត់ផ្គង់ទៅឲ្យយីហោរបស់អាមេរិកដែលមានដូចជា ហ្គេប និងអូល ណាវី ហើយមានទីតាំងនៅក្នុងខេត្តកណ្តាល បានធ្វើការតវ៉ាជាបន្តបន្ទាប់។ កម្មករកម្មការិនីបាន បង្ហាញពីសេចក្តីត្រូវការមួយក្នុងចំណោមសេចក្តីត្រូវការដទៃទៀត គឺសុំឲ្យមានប្រាក់សំណងអតីតភាពច្រើនជាងអ្វីដែលរោងចក្របានផ្តល់ជូនចំពោះការបញ្ចប់កិច្ចសន្យាការងារក្រោយពីការដូរឈ្មោះរោងចក្រ។

កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ កម្មករ កម្មការិនីប្រមាណជា ៥០០ នាក់បានប្រមូលផ្តុំគ្នានៅកន្លែងបញ្ចេញមតិសាធារណៈដែលមានទីតាំងនៅកណ្តាលរាជធានីភ្នំពេញ ហើយមានបំណង ដង្ហែរក្បួនទៅវត្តបុទុម និងដើម្បីដាក់ញត្តិទៅខុទ្ទការល័យនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីស្នើ សុំឲ្យមានដំណោះស្រាយ។ ភ្លាមៗនោះពួកគេក៏ត្រូវបានចោមរោមដោយកងកម្លាំងប្រមាណ ២០០ ទៅ ៣០០នាក់ត្រៀមជាស្រេចសម្រាប់ការបំបែកបាតុកម្ម ហើយដែលបានរង់ចាំនៅជិតៗនោះ និងបានហាមឃាត់មិនឲ្យកម្មករដើរចេញពីកន្លែងបញ្ចេញមតិសាធារណៈ។ បន្ទាប់ពីការប្រឈមមុខមួយសន្ទុះមានការយល់ព្រមថា អ្នកតំណាងចំនួន ២០នាក់ នឹងត្រូវអនុញ្ញាតឲ្យចាកចេញពីកន្លែងបញ្ចេញមតិជាសាធារណៈ និងអាចដើរទៅដាក់ញត្តិនៅវត្តបទុម។

បន្ទាប់ពីបានដាក់ញត្តិនៅវត្តបទុមរួច អ្នកតំណាងទាំង២០នាក់ ដែលរួមមាន លោក វ៉ុង ឈុន និង លោក ឡុង បញ្ញា ដែរនោះ បានបដិសេធការស្នើសុំរបស់ប៉ូលីសឲ្យបំបែកចេញពីសួនសាធារណៈ ដោយពន្យល់ថាពួកគេចង់សម្រាកមួយរយៈបន្ទាប់ពីបានដើរឆ្លងកាត់ទីក្រុងនោះ។ នគរបាល និងទាហានបានហ៊ុមព័ទ្ធ លោក វ៉ុង ឈុន ជាមួយគ្នានេះមានក្រុមកម្មករព្យាយាមការពាររូបលោកចេញពីកន្លែងនោះ ដោយភ័យខ្លាចថាលោកនឹងត្រូវបានចាប់ខ្លួន។ បន្ទាប់ពីមានការជ្រួលច្របល់ មានក្រុមចម្រុះរបស់កម្លាំងនគរបាល និងទាហាន បានងាកទៅរក លោក វ៉ុង បញ្ញា ហើយបានវាយមកលើក្បាលលោកនឹងដំបង។ លោកត្រូវបានគេរុញឲ្យក្រាបទៅលើដី ដោយមានឈាមហូរចេញពីមុខ មុនពេលដែលលោកត្រូវបានគេទាញដៃ និងទាញជើងដាក់ខាងក្រោយរថយន្តនគរបាល រួចក៏បាននាំលោកចេញពីកន្លែងកើតហេតុទៅកាន់ស្នងការនគរបាលរាជធានីភ្នំពេញ។ បន្ទាប់មក លោក វ៉ុង បញ្ញា ត្រូវបានដោះលែងនៅម៉ោង ១០ យប់ ថ្ងៃទី១១ ខែ កក្កដា និងត្រូវបានយកទៅព្យាបាលរបួសលើមុខ និងថ្ពាសមុនពេលត្រលប់ទៅផ្ទះជួបជុំគ្រួសាររបស់លោកវិញ។

## គំរូមួយនៃអំពើហិង្សា

ការប្រើអំពើហិង្សារបស់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ដើម្បី បង្ក្រាបបាតុកម្ម ដូចដែលបានធ្វើកាលពីថ្ងៃទី១១ ខែ កក្កដា គឺតែងកើតមានជា ញឹកញាប់ និងគ្មានករណីលើកលែង។ កាលពីខែ កុម្ភៈ ឆ្នាំ ២០១២ អំឡុងពេលមានការតវ៉ានៅរោងចក្រក្នុងខេត្តស្វាយរៀង អភិបាល ក្រុង លោក ឈូក បណ្ឌិត បាន បាញ់ប្រហារលើក្រុមបាតុករ បណ្តាល

ឲ្យកម្មការិនីរោងចក្រ ៣នាក់ រងគ្រោះថ្នាក់។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ ក្នុងអំឡុងការធ្វើបាតុកម្មក្នុងពេលដែលសាលាឧទ្ធរណ៍កំពុងធ្វើសវនាការចំពោះករណី ស្រ្តីអ្នកភូមិបឹងកក់ចំនួន ១៣នាក់ អាជ្ញាធរបានវាយដំមកលើប្រជាពលរដ្ឋយ៉ាងហោចណាស់ ៣ នាក់ ដែលក្នុងនោះមាន ក្មេងស្រីអាយុ ១១ ឆ្នាំក្មេងប្រុសអាយុ ១៤ឆ្នាំ និងស្រ្តីដែលមានអាយុ ២៥ឆ្នាំ ដែលត្រូវជា ប្អូនស្រីរបស់ស្រ្តីម្នាក់ក្នុងចំណោមស្រ្តីទាំង១៣នាក់ និងត្រូវបានរាយការណ៍ថាបានរលូតកូន ដោយសារតែកងនគរបាលសន្តិសុខម្នាក់បានទាត់ចំពោះរបស់នាង។

## សេរីភាពនៃការជួបប្រជុំ និង ច្បាប់ស្តីពីបាតុកម្ម

សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាព ជួបប្រជុំត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (ស.ស.ស.ម) និ ងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន)។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ ចែងថា ប្រជាពលរដ្ឋខ្មែរគ្រប់រូប "មាន សិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការ ជួបប្រជុំ" ឯមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញក៏បានចែងដែរថាកម្ពុជាទទួលស្គាល់ និង គោរពសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា និងអនុសញ្ញាទាំងឡាយណាដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។

មាត្រា២១ នៃ ក.អ.ស.ព.ន បន្ថែម ទៅលើការទទួលស្គាល់សិទ្ធិនៃការជួបប្រជុំដោយសន្តិភាពបានចែងស្តីពីសេចក្តីណែនាំស្តីពីការដាក់កំហិតដែលអាចមានចំពោះសេរីភាពខាងការជួបប្រជុំ ដោយចែងថា " គ្មានការដាក់កំហិតមកលើការអនុវត្តន៍សិទ្ធិនេះ លើកលែងតែការ រិតត្បិតដែលកំណត់ដោយច្បាប់ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យពាក់ព័ន្ធនឹងផលប្រយោជន៍ផ្នែកសន្តិសុខជាតិ ឬ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈឬ សីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃតែប៉ុណ្ណោះ" ។

ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី (ច្បាប់បាតុកម្ម) រៀបរាប់លម្អិតពីការធានាដោយរដ្ឋធម្មនុញ្ញចំពោះសេរីភាពក្នុងការជួបប្រជុំ ដោយ កំណត់និយមន័យ បាតុកម្មថា សំដៅលើការប្រមូលផ្តុំគ្នា ឬការដង្ហែរក្បួនដោយមនុស្សមួយក្រុមដើម្បីទាមទារ តវ៉ា ឬ សម្តែងជាសាធារណៈនូវមនោសញ្ចេតនា គំនិត ឬ ឆន្ទៈដោយអហិង្សា។ ដោយហេតុថាច្បាប់មិនបានរាប់បញ្ចូលនូវ ការប្រមូលផ្តុំគ្នាទាក់ទងនឹងករណីជម្លោះការងារ នៅក្នុង ឬ ក្បែររបងរោងចក្រ ឬ សហគ្រាស ប៉ុន្តែការការពារដែលធានាដោយច្បាប់បាតុកម្មដែលពាក់ព័ន្ធនឹង ការប្រមូលផ្តុំដោយសន្តិវិធីគឺអាចយកមកអនុវត្ត ក្នុងករណីនេះបាន ដោយសារតែការធ្វើបាតុកម្មនេះនៅឆ្ងាយពីរោងចក្រតែណាន។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការប្រើអំពើហិង្សាហួសហេតុរបស់កងកម្លាំងនគរបាលក្នុងបាតុកម្មថ្ងៃទី១១ ខែ កក្កដា បង្ហាញយ៉ាងជាក់លាក់ពីគំរូ នៅកម្ពុជា ដែលអាជ្ញាធរកំពុងតែរំលោភបំពានបទដ្ឋានការពារទាំងកម្រិតជាតិ និងអន្តរជាតិមកលើសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី តាមរយៈការកើនឡើង នៃការបង្ក្រាបហ្វូងបាតុករ និង កើនឡើងនៃការប្រើអំពើហិង្សា ដើម្បីបំបិទការរិះគន់។

រដ្ឋាភិបាល គួរតែចាត់វិធានការជាបន្ទាប់ដើម្បីធានាថាបញ្ញត្តិនៃសេរីភាពខាងការជួបប្រជុំនៅក្នុងច្បាប់ជាតិ និងអន្តរជាតិត្រូវបានគោរព ព្រមទាំងធានាថាច្បាប់បាតុកម្មមិនត្រូវបាន មន្ត្រីអនុវត្តច្បាប់យកទៅប្រើក្នុងផ្លូវខុស។ ដើម្បីឲ្យសម្រេចបាននូវគោលបំណងនេះ រដ្ឋាភិបាល គួរតែធានាថា អាជ្ញាធររាជធានី និង មន្ត្រីអនុវត្តច្បាប់ទទួលបានការបណ្តុះបណ្តាលសមស្របស្តីពីវិសាលភាពនៃច្បាប់បាតុកម្ម និងគោលការណ៍នៃសេរីភាពខាងការជួបប្រជុំ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង កញ្ញា សន រ៉ាមណា តាមរយៈទូរស័ព្ទ (+៨៥៥ (0) ១៧ ៦៥ ៥៥ ៩១) ឬ អ៊ីម៉ែល ramanasorn@cchrcambodia.org ឬ លោក ចន ខូឡែន (+៨៥៥ (0) ៨៩ ៥៨ ៣៥ ៩០) ឬអ៊ីម៉ែល johncoughlan@cchrcambodia.org ។**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
CC BY NC SA